អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០០៩

# <u>សេចក្តីប្រកាសព័ត៌មាន</u>

ដោយអនុលោមទៅតាម ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) និង កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ និងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ថ្ងៃនេះប្រធានការិយាល័យរដ្ឋបាលស្តីទី បានបញ្ជូនសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងករណី ខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ដូចមានចែងនៅក្នុងវិធាន៧១ នៃវិធានផ្ទៃក្នុង ទៅកាន់សហ ព្រះរាជអាជ្ញាហើយ។

នៅក្នុងសេចក្តីពិចារណានេះ អង្គបុរេជំនុំជម្រះ បានប្រកាសថាខ្លួនមិនអាចរកសម្លេងគាំទ្រពីចៅក្រមបួន រូបយ៉ាងតិច ដើម្បីសម្រេចទៅលើករណីខ្វែងយោបល់នេះបានឡើយ។ នៅពេលដែលអង្គបុរេជំនុំជម្រះមិន អាចឈានដល់ការធ្វើសេចក្តីសម្រេចលើការខ្វែងយោបល់គ្នា ដែលបាននាំយកមកដោះស្រាយនូវចំពោះមុខ ខ្លួននោះ វិធាន៧១ (៤) (គ) នៃវិធានផ្ទៃក្នុង បានចែងថា កិច្ចរបស់សហព្រះរាជអាជ្ញាអន្តរជាតិត្រូវតែយក ទៅអនុវត្ត។ ក្នុងករណីនេះគឺមានន័យថា សហព្រះរាជអាជ្ញាភាគីអន្តរជាតិ អាចបញ្ជូនដីកាសន្និដ្ឋានបញ្ជូន ឲ្យស៊ើបសួរថ្មី ទៅកាន់សហចៅក្រមស៊ើបអង្កេត ដើម្បីបើកការស៊ើបអង្កេតតាមនីតិវិធីច្បាប់។

សំណៅសាធារណៈមានកោសលុប សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើករណីខ្វែងយោបល់គ្នា រវាងសហព្រះរាជអាជ្ញា ដូចមានចែងនៅក្នុងវិធាន៧១ នៃវិធានផ្ទៃក្នុង ក៏ដូចជាយោបល់ភាគច្រើននិងភាគ តិចរបស់អង្គបុរេជំនុំជម្រះ បានចុះផ្សាយនៅក្នុងគេហទំព័ររបស់អ.វ.ត.ក។

http://www.eccc.gov.kh/khmer/court_doc.list.aspx?courtDocCat=ptc_docs